**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ក្រសួងធនធានទឹក និងឧតុនិយម | ក្រសួងអភិវឌ្ឍន៍ជនបទ

# សេចក្តីប្រកាសព័ត៌មានរួម ស្តីពី
# កិច្ចប្រជុំត្រី-វិស័យលើកទី៣ ស្តីពី កសិកម្ម-ទឹក-ជនបទ

នារសៀលថ្ងៃព្រហស្បតិ៍ ៤រោច ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០២៤ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ **ឯកឧត្តម ឆាយ ឫទ្ធិសែន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ឯកឧត្តម ឌិត ទីណា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងឯកឧត្តម ថោ ជេដ្ឋា រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម** បានរួមគ្នាដឹកនាំកិច្ចប្រជុំត្រី-វិស័យលើកទី៣ ស្តីពីកសិកម្ម-ទឹក-ជនបទ ដើម្បីពិនិត្យវឌ្ឍនភាពការងារសម្របសម្រួលការអនុវត្តកម្មវិធីគោលនយោបាយអាទិភាព និងសកម្មភាពដែលពាក់ព័ន្ធនឹងសហគមន៍កសិកម្មទំនើប សហគមន៍កសិករប្រើប្រាស់ទឹក និងភូមិគំរូ។ កិច្ចប្រជុំនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ ក្រុមការងារត្រី-វិស័យ កសិកម្ម-ទឹក-ជនបទ លេខាធិការដ្ឋាន និងមន្ត្រីជំនាញនៃក្រសួងទាំង៣។

ក្នុងប្រសាសន៍ស្វាគមន៍ **ឯកឧត្តម ឆាយ ឫទ្ធិសែន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ** បានជម្រាបថា កិច្ចប្រជុំថ្ងៃនេះមានសារៈសំខាន់ណាស់ ដើម្បីឆ្លើយតបតាមទស្សនៈវិស័យរបស់រាជរដ្ឋាភិបាល ក្នុងការជំរុញឲ្យមានកិច្ចសហការជិតស្និទ្ធ ព្រមទាំងបង្កើនប្រសិទ្ធភាព និងសហថាមពល សំដៅគាំទ្រដល់ការលើកកម្ពស់ និងកែលម្អជីវភាពប្រជាជនតាមសហគមន៍មូលដ្ឋាន ជាពិសេសជួយដល់កម្មវិធីអភិវឌ្ឍន៍រួមគ្នា កសិកម្ម-ទឹក-ជនបទ ដើម្បីពន្លឿនការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានឱ្យទទួលបានអត្ថប្រយោជន៍ជាអតិបរមា។

**ឯកឧត្តម ឌិត ទីណា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** បានសម្តែងនូវភាពជឿជាក់យ៉ាងមុតមាំចំពោះវឌ្ឍនភាពនៃក្រុមការងារត្រី-វិស័យ ដែលបានឈានដល់ដំណាក់កាលជ្រើសរើសសហគមន៍គោលដៅ ដើម្បីចាប់ផ្តើមអនុវត្តរួមគ្នា និងមានការប្រុងប្រៀបរៀបចំផែនការបានយ៉ាងល្អិតល្អន់។ កិច្ចសហប្រតិបត្តិការរួមគ្នារវាងក្រសួងទាំង៣នេះនឹងក្លាយទៅជាយន្តការថ្មីមួយ ដើម្បីដោះស្រាយបញ្ហាប្រឈមរួមនៅថ្នាក់មូលដ្ឋានប្រកបដោយប្រសិទ្ធភាពខ្ពស់ ដែលនឹងជះឥទ្ធិពលរយៈពេលវែងជាវិជ្ជមានដល់សហគមន៍ផងដែរ។

**ឯកឧត្តម ថោ ជេដ្ឋា រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម** បានសម្តែងការសាទរ ចំពោះការខិតខំប្រឹងប្រែង និងកិច្ចសហការរបស់ក្រសួងទាំង៣ ដើម្បីធ្វើឱ្យគំនិតផ្តួចផ្តើមលេចចេញជាផ្លែផ្កា តាមរយៈការអនុវត្តការងាររួមគ្នាប្រកបដោយការសម្របសម្រួលល្អ និងបរិយាបន្ន។ **ឯកឧត្តមរដ្ឋមន្ត្រី** ក៏បានកោតសសើរដល់ក្រុមការងារត្រី-វិស័យ កសិកម្ម-ទឹក-ជនបទ និងលេខាធិការដ្ឋានរបស់ខ្លួនដែលបានយកចិត្តទុកដាក់បំពេញតួនាទីប្រកបដោយការទទួលខុសត្រូវខ្ពស់ និងវិជ្ជាជីវៈ។

បន្ទាប់ពីស្តាប់របាយការណ៍ និងសំណើរបស់ក្រុមការងារត្រី-វិស័យ **ឯកឧត្តមរដ្ឋមន្ត្រី** ទាំង ៣ក្រសួង បានឯកភាពនូវចំណុចដូចខាងក្រោម៖

១. របាយការណ៍វឌ្ឍនភាពការងារ និងលទ្ធផលចុះសិក្សាស្វែងយល់សហគមន៍គោលដៅរបស់ក្រុមការងារត្រី-វិស័យ កសិកម្ម-ទឹក-ជនបទ
២. ការកំណត់ជ្រើសរើសសហគមន៍គោលដៅចំនួន ៦សហគមន៍ ដោយបែងចែកជា ២ជំហាន សម្រាប់ការអនុវត្តសាកល្បងលើសកម្មភាពរួមគ្នាដោយចាប់ផ្តើមអនុវត្តសកម្មភាពចាប់ពីឆ្នាំ២០២៥
៣. ការអនុវត្តអន្តរាគមន៍រួមគ្នាចំពោះសហគមន៍គោលដៅអាទិភាពចំនួន ៤ ក្នុងជំហានទី១ ដោយចាប់ផ្តើមរៀបចំផែនការសកម្មភាពច្បាស់លាស់ ដើម្បីអនុវត្តពីត្រីមាសទី១ ឆ្នាំ២០២៥
៤. ការសិក្សាស្វែងយល់ទីតាំងគោលដៅផ្សេងទៀតដែលមានសក្តានុពល ដើម្បីជ្រើសរើសជាសហគមន៍សម្រាប់អនុវត្តនៅជំហានបន្ទាប់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបងប្អូនសាធារណជនជ្រាបជាព័ត៌មាន៕

ថ្ងៃព្រហស្បតិ៍ ៤រោច ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៤

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងអភិវឌ្ឍន៍ជនបទ